ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
20-Aug-2009, 08:21
ម៉ោង (Time/Heure):
Chanthan Phok

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
20-Aug-2009
Chanthan Phok

# ឯកសារ CD-Cam បង្ហាញថា អ្នកទោស ១៧៧នាក់ត្រូវបានដោះលែងពីស-២១

ដោយ DOUGLAS GILLISON
THE CAMBODIA DAILY

ឯកសារស្តីពីការនៅរស់រានមានជីវិតមិនបានកំណត់អាយុរបស់ ហាន ង៉ូវ ទេ ជា"ក្មេងប្រុស"ម្នាក់ក្នុងចំណោមអ្នកទោសចំនួន ៤៩ នាក់ដែលត្រូវបានដោះលែងពីពន្ធនាគារស-២១ កាលពីថ្ងៃទី២០ខែធ្នូ ឆ្នាំ១៩៧៥ ។

យោងតាមឯកសារក្នុងទូនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បានអោយដឹងថា ក្រុមអ្នកទោសជាមួយ ហាន ង៉ូវ ដូចគ្នានឹងអ្នកទោស២៨នាក់ ដែលត្រូវបានដោះលែងនៅថ្ងៃផ្សេងៗគ្នារហូតដល់ថ្ងៃទី១៥ខែកុម្ភៈ ឆ្នាំ១៩៧៦ ។ ហើយរយៈពេលមួយឆ្នាំកន្លះក្រោយមកនៅថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ១៩៧៧ភ្លាមៗនោះក្រោយមក ទាហានចំនួន១០០នាក់ រួមមានស្ត្រីម្នាក់ ដែលអ្នកទាំងអស់មានអាយុពី១៧ឆ្នាំដល់៣៨ឆ្នាំ បានដើរចេញពីទីដីខ្មោងងឹតនៃកម្ពុជាប្រជាធិបតេយ្យ ។

ចំពោះមនុស្សដទៃទៀត នេះប្រហែលជាការភ្ញាក់ផ្អើលមួយ ។

តទៅទំព័រ៧

**ឯកសារ CD-Cam...**

ពន្ធនាគារស-២១ ដែលជាសាខាពិសេសរបស់កងកំលាំងខ្មែរក្រហមនៅក្នុងទីក្រុងភ្នំពេញដែលគេហៅថា ទួលស្លែងនោះ គេតែងតែដឹងថា ជាទីកន្លែងដែលគ្មាននរណាម្នាក់មានជីវិតរស់នៅទេ ជាទីដែលអ្នកទោសរាប់ពាន់នាក់ត្រូវបានសំលាប់ដោយសារសេចក្តីសំរេចដែលចៀសមិនរួចរបស់បក្សកុម្មុយនិស្តកម្ពុជា ។

លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា បានមានប្រសាសន៍នៅសប្តាហ៍នេះថា ក្នុងចំណោមអ្នកទោសចំនួន១៧៧ នាក់ ដែលបច្ចុប្បន្ននេះមជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា ត្រូវបានដោះលែងពីពន្ធនាគារស-២១នោះ មកដល់ពេលនេះក្រុមអ្នកស្រាវជ្រាវបានជួបមនុស្សម្នាក់ ដែលជាឪពុករបស់កូន៦នាក់នៅក្នុងខេត្តកណ្តាល ។

មនុស្សទីពីរ ដែលការឃុំខ្លួនរបស់គាត់មិនទាន់ត្រូវបានអះអាងនៅឡើយ កំពុងតែទទួលការសំភាសន៍កាលពីថ្ងៃពុធដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅក្នុងដីកាចោទប្រកាន់របស់ពួកគេកាលពីថ្ងៃទី៨ ខែសីហា លើ កាំង ហ្គិចអ៊ាវ ហៅឌុច ជាប្រធានពន្ធនាគារស-២១ សំរាប់រយៈពេលជាច្រើននៃវត្តមានពន្ធនាគារនេះ ក្រុមសហចៅក្រមស៊ើបអង្កេតនៅសាលាក្តីខ្មែរក្រហមបានគាំទ្រទស្សនៈថា មានអ្នកទោសមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់ ។

ក្រុមចៅក្រមទាំងនោះបានរកឃើញថា "ទោះបីសាក្សីម្នាក់បានអះអាងថា គាត់អាចចេញពីពន្ធនាគារស-២១ក៏ដោយ ក៏ភស្តុតាងជាច្រើនបង្ហាញឱ្យឃើញដែរថា គោលនយោបាយនៅពន្ធនាគារស-២១គឺថាគ្មានអ្នកទោសណាម្នាក់អាចត្រូវបានដោះលែងទេ" ។

ពួកគេបាននិយាយថា "នេះត្រូវបានអះអាងដោយកស្សិណសាក្សីថា បណ្តាអ្នកទោសដែលនាំយកទៅកាន់ពន្ធនាគារស-២១ ដោយសារមានកំហុសនោះត្រូវបានសំលាប់ចោលដើម្បីធានាការសំងាត់ និងសន្តិសុខ ។ ឌុចក៏បានអះអាងដែរថា គាត់បានព្យាយាមដោះលែងអ្នកទោសជាច្រើននាក់ជាច្រើនដង ប៉ុន្តែបរាជ័យ" ។

នៅក្នុងការសិក្សាកាលពីឆ្នាំ១៩៩៩ ដ៏គួរអោយកត់សំគាល់របស់គាត់អំពីបណ្ណសារដ្ឋាននៅទួលស្លែងមានឈ្មោះថា "សំឡេងចេញពីពន្ធនាគារស-២១" អ្នកប្រវត្តិសាស្ត្រឈ្មោះ ដេវីត ឆានឡឺ ក៏បានសរសេរដែរថា "គ្មាននរណាម្នាក់ទទួលបានការដោះលែងទេ" ។

នៅក្នុងការសារភាពនៅពន្ធនាគារស-២១និយាយទៅកាន់ ឌុច ដែលត្រូវបានលើកឡើងដោយលោក ឆានឡឺ អ្នកទោសម្នាក់និយាយថា "ខ្ញុំដឹងថា ចំពោះការចូលពន្ធនាគារស-២១មានផ្លូវតែមួយប៉ុណ្ណោះ ។ ចំពោះការចេញវិញ មិនដែលមានទេ" ។

ទោះជាយ៉ាងណាក៏ដោយ លោក ឆាំង យុ បានមានប្រសាសន៍នៅក្នុងកិច្ចសំភាសន៍នៅសប្តាហ៍នេះថា ឯកសារអំពីការដោះលែងនៅពន្ធនាគារស-២១ត្រូវគេដឹងជាយូរមកហើយថានៅមានសល់ ។

លោក ឆាំង យុ បានបង្ហាញឱ្យដឹងកាលពីថ្ងៃអង្គារថា "ទាំងនេះគឺជាឯកសារដែលនៅពន្ធនាគារនោះកាលពីរយៈពេល៣០ឆ្នាំមុន" ។

លោកបានមានប្រសាសន៍ថា "យើងបានផ្សព្វផ្សាយឯកសារនោះគ្រប់ពេល ប៉ុន្តែមិនទទួលបានការចាប់អារម្មណ៍ទេ ។ វាស្មុគស្មាញណាស់ គេមិនអាចយល់ឯកសារទាំងនោះបានទេ" ។

ចំពោះបណ្តាអ្នកសួរចំលើយនៅទួលស្លែងវិញ ការពិតគឺជារឿយៗស្ទើរតែមិនទាក់ទងគ្នា ។ មានការធ្វើទារុណកម្មរហូតដល់ចំលើយសារភាពរបស់អ្នកទោសត្រឹមត្រូវ ហើយឆាប់ៗក្រោយមកក៏មានការសំលាប់ ។

ទោះជាយ៉ាងណាក៏ដោយ យោងតាមលោក ឆាំង យុ បានឱ្យដឹងថា យ៉ាងហោចណាស់នៅក្នុងករណីមួយចំនួនមានការពិភាក្សាក្នុងចំណោមបុគ្គលិកពន្ធនាគារស-២១ថាតើអ្នកជាប់ឃុំម្នាក់ពិតជាសមនឹងដោះលែងឬយ៉ាងណា ។

នៅក្នុងសំណើកាលពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ អោយមានការដោះលែងទាហានអាយុ២៣ឆ្នាំម្នាក់ បុគ្គលិកនៅពន្ធនាគារស-២១បានសរសេរថា "ឈ្មោះនេះបានផ្តាច់ខ្លួនពីអង្គភាពរបស់គាត់ចំនួន២ដង ។ ម្តងគាត់ធ្វើដោយខ្លួនឯង និងម្តងទៀតដោយសារសកម្មភាពរបស់មនុស្សម្នាក់ឈ្មោះ "សៀ" ។ ឈ្មោះនេះទើបតែជួបប្រទះការឈ្លានីស" ។

យោងតាមលោក ឆាំង យុ បានអោយដឹងថា អ្នកសរសេរនោះបានបញ្ចប់ថា "សូមអង្គការមេត្តាដោះលែងឈ្មោះនេះ" ។ លិខិតនោះបានទទួល "ការឯកភាព" នៅថ្ងៃដដែលនោះ ។

នៅថ្ងៃទី១៥ ខែកុម្ភៈក្នុងឆ្នាំនោះ ឯកសារស្រដៀងគ្នាមួយបានបញ្ជាអោយបន្តឃុំខ្លួនទាហានអាយុ២១ឆ្នាំម្នាក់និយាយថា "បុរសនេះមានអាកប្បកិរិយាប្រកបដោយល្បិចកល ហើយបដិសេធមិនទទួលការអប់រំឡើងវិញ ហើយគាត់មានសកម្មភាពមិនល្អ ។ សូមអង្គការដាក់បុរសនេះក្នុងពន្ធនាគារឥឡូវនេះ" ។

កាលពីថ្ងៃទី៨ ខែមីនា ជាខែតែមួយដែល ឌុច បានត្រួតត្រាពន្ធនាគារស-២១ ទោះជាយ៉ាងណាឯកសារនេះត្រូវបានសរសេរថា "ដោះលែង" ។

បន្ទាប់ពីចាប់ផ្តើមប្រតិបត្តិការនៅខែតុលាឆ្នាំ១៩៧៥ នោះពន្ធនាគារស-២១បានផ្លាស់ប្តូរចុះឡើងៗរវាងទីកន្លែងពីរនៅកាច់ជ្រុងផ្លូវលេខ១១៣និងលេខ៣៦០ និងនៅអតីតស្នងការដ្ឋាននគរបាលនៅផ្លូវ៥១ជិតផ្សារថ្មី ។

កាលពីខែមេសាឆ្នាំ១៩៧៦ ពន្ធនាគារនេះស្ថិតនៅកន្លែងចុងក្រោយរបស់ខ្លួន គឺអតីតសាលា លីសេ ពញាយ៉ាត នៅផ្លូវលេខ១១៣ក្នុងសង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ។

សាខាពន្ធនាគារស-២១ស្ថិតនៅជើងឯក ជាកន្លែងដែលគេបានសំលាប់មនុស្សជាច្រើននាក់ និងពន្ធនាគារស-២៤ ឬពន្ធនាគារព្រៃស ជាកន្លែងដែលគេឃុំខ្លួនមនុស្សថ្នាក់ទាប ។

លោក ឆាំង យុ បានមានប្រសាសន៍ថា ឯកសារអំពីការដោះលែងមនុស្សពីពន្ធនាគារស-២១ដែលរួមមានបញ្ជីឈ្មោះពីរមាន

00364596

E2/61.3





ចំណាំងជើងថា "ប្រវត្តិរូបសង្ខេបរបស់អ្នកទោសដែលបានដោះលែង" និង "ឈ្មោះអ្នកទោសដែលបានដោះលែង" ត្រូវបានគេប្រទះឃើញនៅក្នុងឯកសារនៅទួលស្លែង ។

លោក ឆាំង យុ បានមានប្រសាសន៍ថា លោកជឿថា បញ្ជីឈ្មោះទាំងនេះនិយាយអំពីអ្នកទោសជាប់ឃុំនៅពន្ធនាគារស-២១ មិនមែននៅកន្លែងផ្សេងទៀតទេ ។ រហូតមកដល់ពេលនេះគ្មានឯកសារណាមួយនៅទួលស្លែងដែលត្រូវបានគេត្រួតពិនិត្យជាប់ពាក់ព័ន្ធនឹងអ្នកទោសនៅកន្លែងផ្សេងទេ ។

សាក្សីម្នាក់ដែលត្រូវបានស្រង់សំដីដោយចៅក្រមស៊ើបអង្កេត លោក ម៉ាសែល ឡឺម៉ុង និងលោក យូ ប៊ុនឡេង បាននិយាយថា "គ្មានអ្នកទោសណាម្នាក់អាចត្រូវបានដោះលែងពីពន្ធនាគារស-២១ ដោយគ្មានការអនុញ្ញាតពីឌុចទេ" ។

ទោះជាយ៉ាងណា លោក ឆាំង យុ បានមានប្រសាសន៍ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនទាន់បានកំណត់ជាចុងក្រោយនូវកំរិតនៃការជាប់ពាក់ព័ន្ធរបស់ឌុចនៅក្នុងសេចក្តីសំរេចដោះលែងអ្នកទោសនោះទេ ។

លោកបានមានប្រសាសន៍ថា ការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលើអ្នកទោសដែលត្រូវបានដោះលែង ដែលវិទ្យុសំលេងសហរដ្ឋអាមេរិកបានផ្សាយជាលើកដំបូងកាលពីថ្ងៃសុក្រនោះ បានចាប់ផ្តើមកាលពីឆ្នាំ២០០៣ ។

លោកបានមានប្រសាសន៍ថា ឯកសាររបស់ខ្មែរក្រហមបានកត់ត្រាមូលហេតុចំពោះការឃុំខ្លួនអ្នកទោស ប៉ុន្តែមិនបាននិយាយអំពីហេតុផលចុងក្រោយចំពោះការដោះលែងអ្នកទោសទេ ។

ឯកសារនានាបង្ហាញថា ចារកម្មអាយុ២៣ឆ្នាំម្នាក់ត្រូវបានដោះលែងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៥ ។

លោក ឆាំង យុ បានមានប្រសាសន៍ថា "ជាធម្មតាពួកគេសំលាប់ចារកម្ម ប៉ុន្តែចារកម្មរូបនេះត្រូវបានដោះលែង ។ យើងមិនដឹងពីមូលហេតុទេ" ។

លោកបានមានប្រសាសន៍ថា នៅពេលដែលអរិភាពជាមួយវៀតណាមបានកើនឡើងនៅឆ្នាំ១៩៧៧នោះ ខ្មែរក្រហមប្រហែលជាបានចាប់ផ្តើមផ្តោតលើសត្រូវខាងក្រៅច្រើនជាងការលុបបំបាត់កម្មាភិបាលរបស់ពួកគេផ្ទាល់ ដែលធ្វើអោយរបបនេះចុះខ្សោយ ។

លោកបានបន្ថែមថា ការដោះលែងក៏ប្រហែលជាដើម្បីបំពេញចិត្តអ្នកទទួលបន្ទុកផងដែរ ។

"ខ្ញុំអាចទុកអ្នក ។ ខ្ញុំអាចសំលាប់អ្នក ។ ពួកគេមានអំណាចណាស់" ។

នៅក្នុងអ៊ីម៉េលកាលពីថ្ងៃពុធ លោក ឆានឡឺ បានមានប្រសាសន៍ថា លោកមិនបានដឹងអំពីការដោះលែងមនុស្សដែលត្រូវបានគេកត់ត្រាទុក ចេញពីពន្ធនាគារស-២១ទេ ។

លោកបានសរសេរថា "ខ្ញុំស្វាគមន៍ភស្តុតាងឯកសារថ្មី ដែលនឹងធ្វើអោយយើងកាន់តែយល់ដឹងអំពីអ្វីដែលបានកើតឡើងនៅពន្ធនាគារស-២១ ។ លោកបានបន្ថែមថា រូបភាពនៃអំពើអាក្រក់ឃោរឃៅនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យជួនកាលអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

លោកបានសរសេរថា "ខ្ញុំមិនដែលភ្ញាក់ផ្អើលដោយសាររឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ កម្មាភិបាលបក្សដែលយូរៗម្តងមានចិត្តល្អ ការរួចព្រះជន្មរបស់ព្រះសង្ឃមួយចំនួន ការគេចខ្លួនពីអព្ភូតហេតុនេះ... លើកឡើងថា ជួនកាលមានកិច្ចសន្យាណាមួយ ដោយមិនទទួលស្គាល់នូវការពិតតាមវិធីដែលបញ្ហានានាកើតមានឡើង" ។

លោក ឆានឡឺ បានសរសេរថា ចំនួនអ្នកនៅរស់ដែលគេបានដឹងនៅពន្ធនាគារស-២១មានបុរសចំនួន៧នាក់ជាយូរមកហើយ ដែលគេជឿថា នៅក្នុងចំណោមអ្នកទោស១៤នាក់ដែលជាប់នៅពន្ធនាគារនេះ ។

ឥឡូវនេះ លោក ឆាំង យុ ជឿថា អ្នកទោសដែលត្រូវបានដោះលែងទាំង១៧៧នាក់នោះគួរតែគេចាត់ទុកថា ជាអ្នករួចជីវិត ព្រោះពួកគេត្រូវបានជួយសង្គ្រោះដោយអ្នកចាប់ពួកគេ ។

ចំនួនសរុបនៃអ្នកទោសនៅពន្ធនាគារស-២១ក៏មានចំនួនខុសគ្នាដែរ ។ បញ្ជីឈ្មោះអ្នកទោសដែលសាលាក្តីខ្មែរក្រហមបានត្រួតពិនិត្យបង្ហាញថា យ៉ាងហោចណាស់មនុស្សចំនួន១២.៣៨០នាក់ត្រូវបានឃុំខ្លួនហើយសំលាប់ចោល ។ បញ្ជីដែលលោក ឆានឡឺ បានពិនិត្យមានមនុស្សចំនួន១៣.២០៦នាក់ តែលោកបានប៉ាន់ប្រមាណថា ចំនួនមនុស្សទាំងអស់នៅពន្ធនាគារស-២១មានចំនួនប្រហែល១៤.០០០នាក់ ជាតួលេខមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជារក្សាទុកជាយូរមកហើយ ។

លោក ឆាំង យុ បានទទួលស្គាល់ថា "វាមិនមែនជាតួលេខពិតប្រាកដនោះទេ" ។

បន្ទាប់ពីសេចក្តីសំរេចស្តីពីការធ្វើឧទ្ធរណ៍ការកាត់ទោស គេរំពឹងថា សវនាការចំពោះ ឌុច នឹងចាប់ផ្តើមនៅក្នុងឆ្នាំនេះ ។ ជនរងគ្រោះអាចដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីរហូតដល់សវនាការចាប់ផ្តើម ។

លោក ឆាំង យុ បានមានប្រសាសន៍ថា គោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងការស្រាវជ្រាវរបស់ខ្លួនអំពីអ្នកទោសដែលត្រូវបានដោះលែងពីពន្ធនាគារស-២១ គឺមិនមែនដើម្បីប្រមូលពត៌មានអំពីជនរងគ្រោះពីអ្នកដែលត្រូវគេដោះលែងនោះទេ ។

លោកបានមានប្រសាសន៍ថា "ខ្ញុំគិតថា កាលោទប្រកាន់ ឌុច បានដាក់សំពាធថែមទៀតដើម្បីបង្កើនល្បឿនក្នុងការនាំមកនូវរូបភាពច្បាស់លាស់អំពីអ្វីដែលគុកទួលស្លែងបានធ្វើ" ។ "យើងសង្ឃឹមថា វានឹងមានប្រយោជន៍ចំពោះសាលាក្តីខ្មែរក្រហមប្រសិនបើពួកគេត្រូវការពត៌មានបន្ថែម" ។ P & H

Original EN: 00277464-00277465